# សិលាចារឹកប្រាសាទនាងខ្មៅ (K.35)

ប្រាសាទនាងខ្មៅ មានទីតាំងស្ថិតនៅភូមិចារ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ ដែលជាប្រាសាទមានតួប៉មពីរធ្វើអំពីឥដ្ឋ បែរមុខទៅទិសខាងកើត និងឧទ្ទិសដល់ព្រះវិស្ណុ[1] (រូបលេខ១)។ នៅប្រាសាទនេះមានសិលាចារឹកចារជាប់នឹងមេទ្វារប្រាសាទដែលគេបានចុះបញ្ជីលេខ K.35 និងធ្លាប់បានសិក្សាដោយលោក Goerge Coedès ម្តងរួចមកហើយកាលពីឆ្នាំ១៩៥០[2]។ សិលាចារឹកនេះចារឹកជាភាសាសំស្ក្រឹតមានចំនួន១០បន្ទាត់ បើគិតជាស្លោកមានចំនួន៨ស្លោក ចារឹកដោយឆន្ទខុសៗគ្នា ក្នុងនោះ មានស្លោកទី១ ស្លោកទី៤ ស្លោកទី៥ ស្លោកទី៧ និងស្លោកទី៨ ជាប្រភេទអនុឞ្ដុភ៌ឆន្ទ និងស្លោកទី២ជាប្រភេទវសន្តតិលកាឆន្ទ ស្លោកទី៣និងស្លោកទី៦ជាប្រភេទឧបជាតិឆន្ទ។

ស្លោកទី១ រៀបរាប់ពីកិច្ចបង្គំវន្ទាចំពោះព្រះវិស្ណុក្រោមរូបភាពបរមនាមថា **ព្រះស្រីលោកនាថ** ដែលមានន័យថា ជាទីពឹងពុំនាក់ ឬជាសរណវត្ថុរបស់សត្វក្នុងត្រៃភព ហើយស្លោកដដែលបានពោលសសើរព្រះអង្គថា ព្រះឈានត្រឹម៣ជំហានប៉ុណ្ណោះទៅដល់លំហអាកាសវេហា និងដល់ព្រហ្មមណ្ឌល។ ពាក្យ "ស្រីលោកនាថ" គឺជាព្រះនាមមួយរបស់ព្រះនាមព្រះវិស្ណុទាំង១០០០ ហើយក្រៅពីព្រះនាមនេះ នៅសម័យបុរាណយើងឃើញគេមានបង្ហាញព្រះនាមព្រះវិស្ណុជាច្រើនទៀតដូចជា ស្រីបតិ (សិលាចារឹកប្រាសាទចិន) អច្យុត (ប្រាសាទនាងខ្មៅ) វិស្ណុ (ភូមិជ្រៃ) គោវិន្ទម (វត្តគិរីស្តេចចង់) ឧបេន្ទ្រ (ក្តីអង្គ) នារាយណ៍ (ភូមិជ្រៃ) បរាក្រម (ក្តីអង្គ) ត្រីវិក្រម (នាងខ្មៅ)។

ស្លោកទី២ រៀបរាប់អំពី ព្រះរិកីណ៌កិត្តិគុណរបស់ព្រះស្រីលោកនាថ (ព្រះហរិ ឬវិស្ណុ) ដែលមានព្រះកិត្តិនាមល្បីរន្ទឺអស់សាកលត្រៃ ហើយបញ្ជាក់ពីសករាជ (ឆ្នាំ) បញ្ជាក់ដោយ គៃលគ្ន្គសិ (កំពូលភ្នំ ) = ៧ និងអម្វរ (មេឃ) = ០ បាទត្រិវិក្រម (ជំហាន ទាំង៣នៃព្រះបាទទ្រង់) = ៣ ត្រូវនឹងម.ស.ឆ្នាំ ៧០៣ ហើយក៏ត្រូវនឹងគ.ស.៧៨១។ បើដូច្នេះមែន ស្លោកនេះគេរំឭកដល់ព្រឹត្តិការណ៍ចាស់ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ ដែលឡើងសោយរាជ្យនៅគ.ស. ៧៧០ ដល់ ៨៣៤។

ស្លោកទី៣ រៀបរាប់ពីព្រះនាមព្រះបាទស្រីជយវម៌្មន ដោយបញ្ជាក់ពីឆ្នាំដែលទ្រង់ឡើងសោយរាជ្យ ពោល គឺពាក្យថា "**គ្រីកម្ពុជេន្ទ្រះខគរាម្ពរាជ្យោ**" ដែលជាភាសាខ្មែរប្រែថា "រាជរបស់ស្តេចកម្ពុជាក្នុងឆ្នាំកំណត់ដោយ អម្ពុ=៨ គរ=៥ ខ=០ (ម.ស.៨៥០ ត្រូវនឹងគ.ស.៩២៨) ហើយបញ្ជាក់បន្ថែមដោយរៀបរាប់សព្វជាសម្ពស្សខាងកាព្យវិទ្យាថនៅលើព្រះភ្នួងមោលី ប្រដាប់លើព្រះសិរត្នត្បូងវជ្រាពេជ្រ បញ្ចេញពន្លឺរស្មីភ្លឺចិញ្ចែងចិញ្ចាច ព្រះបាទាទាំងគូទ្រដោយបទ្មាជាតិ(ផ្កាឈូក) ព្រះ

---

[1] សូមអានអត្ថបទរបស់លោក សុខ កែវសុវណ្ណារ៉ា ២០២០។

[2] Coedès 1950: 32.

អត្ថបទដោយ៖ កំ វណ្ណារ៉ា

*រាជទាំងឡាយ នរជននានា បានឃើញហើយគោរពកោតខ្លាចអំណាចព្រះដេស្គាដ៏មានសិរីយសសម្បត្តិ។*

*ស្លោកទី៤ រៀបរាប់ពីសេចក្ដីអង់អាចរបស់ព្រះអង្គក្នុងសមរភូមិ ដែលធ្វើឱ្យសត្រូវទាំងអស់ខ្លបខ្លាច ហើយមកចុះចូលព្រមរួមរស់សុខដុមជាមួយព្រះអង្គ។*

*ស្លោកទី៥ រៀបរាប់ពីសេចក្ដីអង់អាចរបស់ព្រះអង្គ តែប្រើវោហាជាកាព្យសាស្ត្រប្រកបដោយពាក្យពេចន៍រស់រវើកពីរោះរណ្ដំដែលក្នុងអត្ថបទកាព្យពោលថា "ពេលប្រយុទ្ធដ៏ស្វិតស្វាញនៅក្នុងយុទ្ធសមរភូមិព្រះអង្គមានអនុភាពខ្លាំងណាស់ សូម្បីផ្ទាំងសិលាដ៏ធំមហិមាក៏ព្រះអង្គអាចគ្រវាត់ (និម្មិត្ត) ដែលផ្ទាំងសិលាដ៏ធំនោះបានបិទបាំងពន្លឺរស្មីរបស់ព្រះសូរ្យាបង្កើតបានជាយប់យន់អន្ធការខ្មៅងងឹតនៅទីងមុខសត្រូវ ធ្វើឱ្យសត្រូវទាំងឡាយសូម្បីមានភ្នែកមិនពិការក៏មិនអាចមើលឃើញបានឬអាចតតាំងច្បាំងយកជ័យជម្នះជាមួយព្រះអង្គបានឡើយ។*

*ស្លោកទី៦ រៀបរាប់ពីសេចក្ដីស្រលាញ់ដោយវោហារប្រៀបធៀប និងព្រះនេត្រព្រះឥសូរ។*

*ស្លោកទី៧ រៀបរាប់ពីការទទួលបានព្រះនាងលក្ស្មីដែលមកពីការកូរមហាសមុទ្រទឹកដោះយកទឹកអម្រឹត។*

*ស្លោកទី៨ រៀបរាប់ចំនួនវោហារកាព្យសាស្ត្រដែលប្រៀបធៀបការបះបោរចម្បាំងរាំងជលផ្សេងៗប្រដូចជាព្យុះព្យោបក់បោកលួចបំបាក់បំផ្លិចបំផ្លាញ ហើយបង្កឡើងគ្រប់ទិសទីទាំងអស់ ពោល គឺគ្រប់ខេត្តដែន តែអ្វីៗទាំងអស់ត្រូវបានបញ្ចប់ទៅវិញដោយឫទ្ធិអំណាច ពោលគឺ សង្គ្រាមយុទ្ធសាស្ត្រ សេចក្ដីអង់អាចក្លាហាន និងគតិបណ្ឌិតរបស់ព្រះអង្គ។*

**អត្ថបទពាក្យចារឹក និងសេចក្ដីប្រែ**

១. ឯមត្ត្រៃលោកជាថាយ យោយតាយតិគក្តិកិះ
ត្រិបឧក្រាន្តឌរណិ វ្យោមប្រហ្មាណ្ឌមឆ្វលះ។

**ប្រែថា៖** *សូមក្រាបថ្វាយបង្គំចំពោះព្រះស្រីលោកនាថ (នមត៌ត្រៃលោកនាថាយ) ព្រះអង្គទ្រង់មានអំណាចរកអ្នកប្រាកដស្មើគ្មានឡើយ (យោយតាយតិគត្តិកិះ) ហើយទ្រង់បានដើរបោះបីជំហាននៅលើធរណី (ត្រិបទក្រាន្តធរណិ) ដល់ក្នុងលំហអាកាសវេហា (វ្យោម) និងដល់ព្រហ្មស្ថាន (ព្រហ្មាណ្ឌមទ្ធលះ)។*

២. ត្រៃលោកជាជមិតិ តរ្វមិមឆ្វជាតិ យុក្តំ ហរិស្រិត្តិកុរជប្រវិតិណ្ឌ៌ាគីត្តីះ
ចាឧត្រិវិក្រាមរុចាម្វរកៃលគ្ននូ៌ស សំលក្សីតោ ភគវតាយុគវិស្តរាន្តាតិ។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

***ប្រែថា៖*** *ព្រះនាមថាស្រីលោកនាថ (ឝ្រីលោកនាថម៌តតិ) ជាព្រះនាមពិតប្រាកដរបស់ព្រះហរិ (ហរិសិ) ទ្រង់មានកិត្តិសព្ទល្បីល្បាញក្នុងត្រៃភព (ត្រិភុវនប្រវិកិណ្ណ៌កីត្តិះ)។ សិរីសួស្តីក្នុងឆ្នាំនៃសកកំណត់សម្គាល់ដោយបាទត្រិវិក្រម* (ជំហានទាំង៣នៃព្រះបាទទ្រង់) *គៃលគ្គង្គសិ* (កំពូលភ្នំ) និងអម្វរ (មេឃ) *(ត្រូវនឹងម.ស.៧០៣ ឬគ.ស.៧៨១)*។

៣. ឩម្រាវជិព្រ្វាត្តមមូធ្ន៌មៅលី  រត្នត្យុតិឡោតិតចាឧបធ្នះ
ត្រីកម្ពុជេន្ទ្រះខគភាម្នាជេ្យរាជ  យឝ្រីជយវម៌្មទេវះ។

***ប្រែថា៖*** *ព្រះរាជាទ្រង់ព្រះនាមថា ព្រះបាទស្រីជយវម៌ទេវ ទ្រង់គឺជាព្រះមហាក្សត្រនៃកម្ពុជ (ឝ្រីកម្ពុជេន្ទ្រះ) ដែលទ្រង់ប្រដាប់ទៅដោយគ្រឿងអាភរណៈ ព្រះបាទទ្រដោយផ្កាឈូក លើព្រះក្អួងមូលីប្រដាប់ដោយមកុដត្បូងពេជ្រ បញ្ចេញពន្លឺត្រចះត្រចង់ឧត្ដុង្គឧត្តមលើក្សត្រដទៃឱ្យខ្វបខ្វាច ហើយទ្រង់បានគ្រងរាជសម្បត្តិនៅក្នុងឆ្នាំសកកំណត់ដោយ អម្ពរ=៨ គរ=ព្រួញ=៥ ខ=លំហ អាកាស=០ ត្រូវនឹងម.ស.៨៥០ ឬគ.ស.៩២៨)*។

៤. អរិវក្ឞស្ឞលោ្រ្ភាន្ត  ត្រីយាសេះ ចាតជាន្ទ្ឞកំ
យស្យ រក្សោក្ពុជេ ប្រីត្យា  យុទ្ធេឞ្វាក្វាក្រយះក្ឞតះ។

***ប្រែថា៖*** *នៅក្នុងចម្បាំង សន្ទុះព្រះខ័នរបស់ទ្រង់វាយសន្ធាប់ទៅលើដើមទ្រូងនៃបច្ចាមិត្រ ដែលបានកៀសខ្លួនយ៉ាងរហ័សមកសុំជ្រកកោនក្រោមផ្កាឈូកនៃដើមទ្រូងរបស់ទ្រង់*។

៥. យុទ្ធេឞុ យេន និម៌្មុក្ត  គាដៅឃៃះ ប្ញវិតាម្វរៃះ
និគាយាំ ធ្ឞប្តកត្រូណាំ  លោចនេឞុ ក្ឞតន្តមះ។

***ប្រែថា៖*** *នៅក្នុងសមរភូមិប្រយុទ្ធ* (យុទ្ធេឞុ) *ព្រះអង្គបានគ្រវាត់* (និម៌្មុក្ត) *បេញទៅនូវផ្ទាំងថ្មដ៏ធំៗមហិមា (គាឌៅឃៃះ) បានបិតបាំងជុំជិតពេញផ្ទៃមេឃ (ប្លវិតាម្វរៃះ) បង្កើតទៅជាងងឹតយប់យន់អន្ធការនៃរាត្រីកាល (និឝាយាំ) នៅចំពោះភ្នែក (លោចនេឞុ) របស់សត្រូវទាំងឡាយ (ទ្ឞប្តគត្រូណាំ)*។

៦. ច្រាក្ឞេជនន្តស្យ វិភាស....  អនន្តកោភេវ ជិតាត្នកោភា
ត្រិនេត្រនេត្រាគ្និតិខាកហាប  ប្រប្វយជិជ្ញខតិក្ឞតា។

***ប្រែថា៖*** *កាលគ្រាមុន មន្តស្នេហ៍....... ប្រៀបបាននឹងមន្តស្នេហ៍ដែលល្អលើសសម្ផស្សរបស់ទ្រង់ ព្រះនេត្រម្ខាងនៃព្រះឥសូរ....*។

៧. ចាណិក្រហមកក្វាំដោ  លក្សោ្យ យោ ម្ឞតមណ្ឌនេ
អភាប្តលក្សី្ម យុទ្ធាក្វៅ  ជ វាហុំ វហ្វមឆ្យត។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

***ប្រែថា៖*** *ទ្រង់ពុំបានយកព្រះហស្តចាប់យកព្រះនាងលក្ស្មីនៅក្នុងការកូរយកទឹកអម្រឹតទេ ទ្រង់បានច្រលំព្រះហស្តចាប់យកព្រះនាងលក្ស្មីពីមហាសមុទ្រនៃចម្បាំង។*

៨. យត្កិត្តិណ្ឌាគ៌ីត្តីបិយោតៃ ក្នា‌ន្តំតាចាត្មិសញ្ចយះ
កោណាបិ និតរាន្ទិក្យុ ជ្វលត្យន្យាបិ កាន្តិភិះ។

***ប្រែថា៖*** *ព្យុះព្យោមារក្ដួចវិលវល់ បានបញ្ឈប់ដោយអំណាចដ៏ខ្លាំងក្លារបស់ទ្រង់ ដែលហាក់កំពុងឆាបឆេះសន្ធោសន្ធៅនៅទូទាំងចតុទិសតាមរយៈសក្តិរបស់ទ្រង់។*


ឯកសារយោង

***សុខ កែវសុវណ្ណារ៉ា***

២០២០, “*ទស្សនៈថ្មីលើប្រាសាទព្រះវិស្ណុ*”, *ផ្សាយអនឡាញនៅក្នុងគេហទំព័រ AMS Khmer Civilization ភ្នំពេញ*

**Coedès, G.**

1950, *Inscription du Cambodge*. Tome II, Paris.




*រូបលេខ១៖ ប្រាសាទនាងខ្មៅ ខេត្តតាកែវ មើលពីមុខខាងកើត (រូបថត៖ លាក់ ស៊ីផាន់ណា)*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*



រូបលេខ២៖ សំណៅផ្តិតសិលាចារឹកប្រាសាទនាងខ្មៅ K.35 (ដោយ៖ កំ វណ្ណាក់)

អរិយធម៌ខ្មែរ
KHMER CIVILIZATION